ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកែប**

-សំណុំរឿងព្រហ្មទណ្ឌលេខ ១០
ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២៣
-សំណុំរឿងជំនុំជម្រះលេខ ១៤
ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣
-សាលក្រមព្រហ្មទណ្ឌលេខ ២៣ ង
ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០២៣

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកែប

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការនៃសាលាដំបូងខេត្តកែប នាថ្ងៃទីសាមសិបមួយ ខែឧសភា ឆ្នាំពីរពាន់ម្ភៃបី វេលាម៉ោងដប់ព្រឹក ដោយមានសមាសភាពៈ

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
-លោក [redacted] ជាចៅក្រមប្រឹក្សា
-លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកែប

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តកែប

**មេធាវី**

-លោក [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សារ៉ុន , [redacted] លុយម៉ា និងឈ្មោះ [redacted] ស៊ីណា ។

**ដើម្បីជំនុំជម្រះលើជនជាប់ចោទៈ**

១-ឈ្មោះ [redacted] សារ៉ុន ភេទប្រុស កើតថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៦ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ សន្តិសុខ ទីកន្លែងកំណើតភូមិ [redacted] ខេត្តកែប ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកែប ឪពុកឈ្មោះ [redacted] សារ៉េត ម្តាយឈ្មោះ [redacted] ជាត នៅលីវ កម្រិតវប្បធម៌ថ្នាក់ទី០៩ ជាអនីតិជន ទោសពីមុនគ្មាន ។

២-ឈ្មោះ [redacted] លុយម៉ា ភេទប្រុស កើតថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៧ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរនៅផ្ទះ ទីកន្លែងកំណើត[redacted] ខេត្តកែប សាសនាព្រះពុទ្ធ ទីលំនៅ



Scanned with CamScanner

បច្ចុប្បន្ននៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប ឪពុកឈ្មោះ [redacted] សំណាង ម្តាយឈ្មោះ [redacted] ថាវី នៅលីវ កម្រិតវប្បធម៌ថ្នាក់ទី០៩ ជាអនីតិជន ទោសពីមុនគ្មាន។

៣-ឈ្មោះ [redacted] ស៊ីណា ភេទប្រុស អាយុ ១៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតភូមិ [redacted] ខេត្តកែប ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកែប ឪពុកឈ្មោះ [redacted] រេន ម្តាយឈ្មោះ [redacted] ស្រី នៅលីវ កម្រិតវប្បធម៌ថ្នាក់ទី០៨ ជាអនីតិជន ទោសពីមុនគ្មាន ។

ជាប់ចោទពីបទ លួច ប្រព្រឹត្តនៅចំណុចដីឡូត៍មួយកន្លែង ស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។

**ដើមបណ្តឹងរដ្ឋប្បវេណី** ឈ្មោះ [redacted] រតនា ភេទប្រុស អាយុ ៤០ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ អ្នកយកព័ត៌មាននៃអង្គភាពខេមបូខាបុស្តិ៍ ទីលំនៅបច្ចុប្បន្ននៅភូមិកែវក្រសាំង សង្កាត់កែប ក្រុងកែប ខេត្តកែប។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១២ អ.យ.ត/២៣ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកែប ។

-បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ៩៧/២៣ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តកែប ។

-បានឃើញ សេចក្តីសម្រេចចាត់តាំងចៅក្រមជំនុំជម្រះ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តកែប ។

-បានឃើញ កំណត់ហេតុសវនាការចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣ ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង០២ យប់ មានករណីលួចមួយបានកើតឡើងបង្កឡើងដោយជនសង្ស័យចំនួន ០៣នាក់ ១.ឈ្មោះ [redacted] សារ៉ុន ភេទប្រុស អាយុ១៧ឆ្នាំ, ២.ឈ្មោះ [redacted] លុយម៉ា ភេទប្រុស អាយុ១៦ឆ្នាំ និងទី៣.ឈ្មោះ [redacted] ស៊ីណា ភេទប្រុស អាយុ១៥ឆ្នាំ ពួកគេបាននាំគ្នាឆ្លោះរបងចូលទៅលួចរបស់របរ នៅក្នុងដីឡូត៍មួយកន្លែងរបស់ឈ្មោះ [redacted] រតនា មុខរបរលក់អីវ៉ាន់ ស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប បាននូវទឹកក្រូចចំនួន១៨ដប បារី១៥កញ្ចប់ មី០៣កំប៉ុង និងដែកកេះចំនួន ៤ ដើម ដោយក្នុងហេតុការណ៍នោះឈ្មោះ [redacted] ស៊ីណា ជាអ្នកចូលទៅលួច ហើយហុចបន្តឲ្យទៅឈ្មោះ [redacted] សារ៉ុន ដើម្បីហុចបន្តឲ្យទៅឈ្មោះ [redacted] លុយម៉ា។

ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## សាលាដំបូងខេត្តកែប

## យល់ឃើញថា

១.កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោងប្រហែល ០២យប់ ពិតជាមានករណីលួចមួយកើតឡើងស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប ដែលប្រព្រឹត្តដោយជនជាប់ចោទ



Scanned with CamScanner

ឈ្មោះ [redacted] សារ៉ុន ភេទប្រុស ឈ្មោះ [redacted] លុយម៉ា ភេទប្រុស និងឈ្មោះ [redacted] ស៊ីណា ភេទប្រុស ពិតប្រាកដមែន ។

២.នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] ស៊ីណា បានឆ្លើយសារភាពថា នៅយប់ថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោងប្រហែល ០២ យប់ ពួកខ្លួនមានគ្នាបីនាក់ មានឈ្មោះ [redacted] សារ៉ុន និងឈ្មោះ [redacted] លុយម៉ា និងរូបខ្លួន ដោយសារឃ្លានក៏បាននាំគ្នាទៅលួចអីវ៉ាន់នៅតូបរបស់ឈ្មោះ [redacted] រតនា ។ ពេលដែលលួចអីវ៉ាន់នោះ ខ្លួនជាអ្នកផ្លោះរបងចូលទៅក្នុងតូបអីវ៉ាន់ ចំណែកឈ្មោះ [redacted] សារ៉ុន និងឈ្មោះ [redacted] លុយម៉ា នៅឈរចាំខាងក្រៅរបង ហើយពេលដែលខ្លួនលួចបានក៏ហុចទៅឱ្យពួកគេទាំងពីរនាក់ជាអ្នកទទួលបន្ត ។ អីវ៉ាន់ដែលលួចបានមាន ទឹកក្រូចចំនួន ១៨ ដប, បារីចំនួន ១៥ កញ្ចប់, មីចំនួន ០៣ កំប៉ុង និងដែកកេះចំនួន ០៤ ដើម ។ នៅពេលដែលលួចបានហើយ ពួកខ្លួនក៏បានយកអីវ៉ាន់ដែលលួចបាននោះទៅដាក់នៅផ្ទះរបស់ ឈ្មោះ [redacted] លុយម៉ា រួចក៏នាំគ្នាហូបមី ផឹកទឹកក្រូចនិងជក់បារីអស់មួយចំនួន ។

៣.នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] លុយម៉ា ហៅលុយ បានឆ្លើយសារភាពថា កាលពីយប់ថ្ងៃទី០៨ កុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោងប្រហែល ០២យប់ ខ្លួននិងមិត្តភ័ក្ត មានឈ្មោះ [redacted] សារ៉ុន និងឈ្មោះ [redacted] លីណា បានដើរទៅលួចអីវ៉ាន់នៅតូបរបស់ឈ្មោះ [redacted] រតនា ។ ពេលដែលទៅដល់តូបលក់អីវ៉ាន់របស់ឈ្មោះ [redacted] រតនា ឈ្មោះ [redacted] ស៊ីណា ហៅធឿន ជាអ្នកផ្លោះរបងចូលលួចអីវ៉ាន់ រីឯខ្លួនឡើងលើរបងចាំទទួលអីវ៉ាន់ និងឈ្មោះ [redacted] សារ៉ុន ជាអ្នកឈរចាំខាងក្រៅរបងដើម្បីចាំទទួលអីវ៉ាន់បន្តពីរូបខ្លួន។ អីវ៉ាន់ដែលពួកខ្លួនលួចបានរួមមាន ទឹកក្រូចចំនួន ១៨ដប, បារីចំនួន ១៥ កញ្ចប់, មី ០៣កំប៉ុង និងដែកកេះចំនួន ០៤ ដើម ។ នៅពេលដែលលួចបានហើយ ពួកខ្លួនក៏បានយកអីវ៉ាន់ទាំងអស់នោះទៅផ្ទះរបស់ខ្លួន រួចក៏បាននាំគ្នាហូបមី ផឹកទឹកក្រូច និងជក់បារីអស់មួយចំនួន ។ ពួកខ្លួនលួចអីវ៉ាន់របស់ ឈ្មោះ [redacted] រតនា ក្នុងគោលបំណងយកមកហូបចំអែតក្រពះតែប៉ុណ្ណោះ ពុំមានបំណងចង់ធ្វើបាប ឬយកទៅលក់បន្តទេ ។

៤.នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] សារ៉ុន បានឆ្លើយសារភាពថា កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោងប្រហែល ០២យប់ រូបខ្លួននិងមិត្តភ័ក្តរបស់ខ្លួនពីរនាក់ផ្សេងទៀត មានឈ្មោះ [redacted] លុយម៉ា និងឈ្មោះ [redacted] ស៊ីណា ហៅ ធឿន បានបបួលគ្នាដើរទៅលួចអីវ៉ាន់នៅតូបរបស់ឈ្មោះ ប៊ិត រតនា ។ ក្នុងពេលធ្វើសកម្មភាព រូបខ្លួននិងឈ្មោះ [redacted] លុយម៉ា នៅឈរចាំខាងក្រៅរបង ចំណែកឯឈ្មោះ [redacted] ស៊ីណា ហៅ ធឿន ជាអ្នកផ្លោះរបងផ្ទះហើយចូលលួចយកអីវ៉ាន់ ក្នុងតូបរបស់ឈ្មោះ [redacted] រតនា ហើយយកអីវ៉ាន់ដែលលួចបាននោះ ហុចមកឱ្យពួកខ្លួនជាអ្នកទទួលបន្ត។ អីវ៉ាន់ដែលលួចបានរួមមាន ទឹកក្រូចវចំនួន ១៨ ដប, បារីចំនួន ១៥កញ្ចប់, មីចំនួន ០៣ កំប៉ុង និងដែកកេះចំនួន ០៤ដើម ។ នៅពេលដែលលួចបានហើយ ពួកខ្លួនក៏បានយកអីវ៉ាន់ដែលលួចបាននោះទៅដាក់នៅផ្ទះរបស់ឈ្មោះ [redacted] លុយម៉ា រួចក៏នាំគ្នាហូបមី ផឹកទឹកក្រូច និងជក់បារីអស់មួយចំនួនដែលលួចបាននោះអស់មួយចំនួន ។ ពួកខ្លួនទៅលួចអីវ៉ាន់របស់ឈ្មោះ [redacted] រតនា ក្នុងគោលបំណងយកមកហូបចំអែតក្រពះតែប៉ុណ្ណោះ ពុំមានបំណងចង់ធ្វើបាបម្ចាស់អីវ៉ាន់ ឬចង់យកទៅលក់បន្តអ្វីទេ ។

៥.តំណាងអយ្យការ បានធ្វើសេចក្តីសន្និដ្ឋានថា មានពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] សារ៉ុន ភេទប្រុស អាយុ ១៧ឆ្នាំ ឈ្មោះ [redacted] លុយម៉ា ភេទប្រុស អាយុ ១៦ឆ្នាំ



Scanned with CamScanner

និងឈ្មោះ [redacted] ស៊ីណា ភេទប្រុស អាយុ ១៥ឆ្នាំ ពីបទ លួច តាមមាត្រា ៣៥៣ និង ៣៥៦ នៃក្រមព្រហ្មទណ្ឌ និងប្ដឹងសុំទៅក្រមជំនុំជម្រះ សម្រេចផ្តន្ទាទោសជនជាប់ចោទទាំងបីនាក់តាមច្បាប់ ។ សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ មានលក្ខណៈត្រឹមត្រូវតាមច្បាប់។

៦.មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ឈ្មោះ [redacted] សារ៉ុន ភេទប្រុស អាយុ ១៧ឆ្នាំ, ឈ្មោះ [redacted] លុយម៉ា ភេទប្រុស អាយុ ១៦ឆ្នាំ និងឈ្មោះ [redacted] ស៊ីណា ភេទប្រុស អាយុ ១៥ឆ្នាំ បានធ្វើសេចក្តីសន្និដ្ឋានការពារកូនក្តីរបស់ខ្លួនថា កូនក្តីរបស់ខ្លួនពិតជាបានប្រព្រឹត្តអំពើលួច ដូចការចោទប្រកាន់ពិតប្រាកដមែន ក៏ប៉ុន្តែការលួចនោះគឺគ្រាន់តែលួច ដើម្បីហូបចំអែតក្រពះតែប៉ុណ្ណោះ ។ សេចក្តីសន្និដ្ឋានរបស់មេធាវីការសិទ្ធិឲ្យជនជាប់ចោទទាំងបីនាក់ បានបង្ហាញឲ្យឃើញថា ជនជាប់ចោទទាំងបីនាក់ ពិតជាបានប្រព្រឹត្តបទល្មើស ដូចការចោទប្រកាន់របស់តំណាងអយ្យការ ពិតប្រាកដមែន ។

៧.យល់ឃើញថា អំពើរបស់ជនជាប់ចោទទាំងបីនាក់ មានធាតុផ្សំបទល្មើសគ្រប់គ្រាន់ពីបទលួចតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

៨.យល់ឃើញថា ផ្អែកតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ បានកំណត់ថាអតិបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាលសម្រាប់ អនីតិជនអាយុចាប់ពី ១៤ឆ្នាំឡើង ហេតុនេះគប្បីតុលាការពិចារណា និងសម្រេចតាមច្បាប់ ។

៩.យល់ឃើញថា ជនជាប់ចោទទាំងបីនាក់នេះ ស្ថិតនៅក្នុងវ័យជាអនីតិជន ហើយទើបតែប្រព្រឹត្តបទល្មើសជាលើកទីមួយ ហេតុដូច្នេះគប្បីតុលាការពិចារណាអំពីស្ថានសម្រាលទោសនិងការព្យួរទោសដល់ជនជាប់ចោទទាំងបីនាក់ តាមមាត្រា ៩៣ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ដើម្បីផ្តល់ឱកាសដល់ជនជាប់ទាំងបីនាក់ បានកែប្រែខ្លួនវិលទៅរស់នៅក្នុងសង្គមឡើងវិញ ។

១០.យល់ឃើញថា មានពិរុទ្ធភាព និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដាក់បន្ទុកលើជនជាប់ចោទ ឈ្មោះ [redacted] សារ៉ុន ភេទប្រុស អាយុ១៧ឆ្នាំ ,ឈ្មោះ [redacted] លុយម៉ា ភេទប្រុស អាយុ ១៦ឆ្នាំ និងឈ្មោះ [redacted] ស៊ីណា ភេទប្រុស អាយុ ១៥ឆ្នាំ ពីបទ លួច ប្រព្រឹត្តនៅចំណុចដីឡូត៍មួយកន្លែង ស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។

១១.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រតនា ដែលជាម្ចាស់អីវ៉ាន់ដែលជនជាប់ចោទឈ្មោះ [redacted] សារ៉ុន,ឈ្មោះ [redacted] លុយម៉ា និងឈ្មោះ [redacted] ស៊ីណា បានលួចនៅក្នុងរឿងនេះបានឆ្លើយបញ្ជាក់យ៉ាងច្បាស់ក្នុងពេលសវនាការថា មិនទាមទារសំណងអ្វីពីជនជាប់ចោទទាំង ០៣នាក់នេះឡើយ ហេតុដូច្នេះតុលាការមិនលើកយកចំណុចនេះមកពិចារណាឡើយ ។

## ហេតុដូច្នេះសម្រេច

១- ផ្តន្ទាទោសជនជាប់ចោទ៖

១-១.ឈ្មោះ [redacted] សារ៉ុន ភេទប្រុស កើតថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៦ (ដែលមានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ០១ (មួយ) ឆ្នាំ តែទោសនេះត្រូវព្យួរធម្មតា ។

១-២. ឈ្មោះ [redacted] លុយម៉ា ភេទប្រុស កើតថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៧ (ដែលមានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ០១ (មួយ) ឆ្នាំ តែទោសនេះត្រូវព្យួរធម្មតា ។

១-៣.ឈ្មោះ [redacted] ស៊ីណា ភេទប្រុស អាយុ ១៥ឆ្នាំ (ដែលមានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ០១ (មួយ) ឆ្នាំ តែទោសនេះត្រូវព្យួរធម្មតា ។



Scanned with CamScanner

ពីបទ លួច ប្រព្រឹត្តនៅចំណុចដីឡូត៍មួយកន្លែង ស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

២. សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សារ៉ុន ,ឈ្មោះ [redacted] លុយម៉ា ,ឈ្មោះ [redacted] ស៊ីណា និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រតនា ប្រកាសជាសាធារណៈនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សារ៉ុន , ឈ្មោះ [redacted] លុយម៉ា ,ឈ្មោះ [redacted] ស៊ីណា និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រតនា ។

*ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។*

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
| --- | --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា និងត្រា |

[redacted]

---

បានឃើញ

**ប្រធានក្រុមប្រឹក្សា**

[redacted]

***បានចម្លងត្រឹមត្រូវតាមច្បាប់ដើម***

ថ្ងៃពុធ ០៣រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

កែប , ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner